- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ព្រះរាជក្រឹត្យ

មាត្រា ១ : ត្រូវបានដាក់មន្ត្រីរាជការឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងឋានន្តរស័ក្តិឧត្តមមន្ត្រីការបរទេសនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ របស់ក្រសួង-ស្ថាប័ន ឱ្យចូលនិវត្តន៍ ដោយនៅរក្សាក្របខ័ណ្ឌនយោបាយដដែលរហូតមានការសម្រេចជាថ្មីពីរាជរដ្ឋាភិបាល មានរាយនាមដូចខាងក្រោម :

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍					
១	**សារ៉ាត់ ខាន់**	ប	រដ្ឋលេខាធិការ	ឧត្តមមន្ត្រី ថ្នាក់លេខ ១	ថ្ងៃខែចូលនិវត្តន៍ ០១-០៤-២០១០
ក្រសួងបរិស្ថាន					
១	**អ៊ូ ស៊ុនអ៊ាន់**	ប	អនុរដ្ឋលេខាធិការ	ឧត្តមមន្ត្រី ថ្នាក់លេខ ៥	ថ្ងៃខែចូលនិវត្តន៍ ០៩-១២-២០០៩
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ					
១	**ជីង ម៉ុនថេង**	ប	អនុរដ្ឋលេខាធិការ	ឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៦	ថ្ងៃខែចូលនិវត្តន៍ ០១-០៣-២០១០
ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល					
១	**ឯក សុនចាន់**	ប	ឋានៈស្មើ រដ្ឋលេខាធិការ	ឧត្តមមន្ត្រី ថ្នាក់លេខ ៥	ថ្ងៃខែចូលនិវត្តន៍ ០១-០៤-២០១០

មាត្រា ២ : ត្រូវបានដាក់មន្ត្រីរាជការឋានន្តរស័ក្តិឧត្តមមន្ត្រីការបរទេស នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ របស់ក្រសួង**ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** ឱ្យចូលនិវត្តន៍ មាននាមដូចខាងក្រោម :

១	**មាស សាអ៊ាន់ឌី**	ប	មន្ត្រីថ្នាក់អនុប្រធាននាយកដ្ឋាន	ឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៣	ថ្ងៃខែចូលនិវត្តន៍ ០១-០៦-២០១០

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរ.ល. ១០០៧. ០៦៥

លេខ: ៥៧ ច.ល
ចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មករា ឆ្នាំ២០១០
អគ្គលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី
ស៊ុន ប៊ុនគេន

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១០

ព្រះរាជក្រឹត្យ

នស/រកត/០១១០/០៦៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្រុមប្រឹក្សាមន្ត្រីគ្រប់គ្រងរដ្ឋបាល

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS

- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដាក់មន្ត្រីរាជការឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួង-ស្ថាប័ន ឱ្យចូលនិវត្តន៍ ដោយនៅរក្សាក្របខ័ណ្ឌនយោបាយដដែលរហូតមានការសម្រេចជាថ្មីពីរាជរដ្ឋាភិបាល មានរាយនាមដូចខាងក្រោម :

ក្រសួងធនធានទឹក និងឧតុនិយម					
១	**លឹម គានហោ**	ប	រដ្ឋមន្ត្រី	**ក.១.១**	**ចូលនិវត្តន៍ពីថ្ងៃទី ០១-០៦-២០១០**
២	**មួង សៅឯន**	ប	អនុរដ្ឋលេខាធិការ	**ក.១.១**	**ចូលនិវត្តន៍ពីថ្ងៃទី ០១-១១-២០១០**
ក្រសួងពាណិជ្ជកម្ម					
១	**គឹម ស៊ីថន**	ប	រដ្ឋលេខាធិការ	**ក.១.១**	**ចូលនិវត្តន៍ពីថ្ងៃទី ០១-០៧-២០១០**
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ					
១	**អ៊ុំ មាន**	ប	រដ្ឋលេខាធិការ	**ក.១.២**	**ចូលនិវត្តន៍ពីថ្ងៃទី ០១-០១-២០១០**
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា					
១	**អ៊ុស្សារ៉ែល ឧស្សាន**	ប	អនុរដ្ឋលេខាធិការ	**ក.១.៤**	**ចូលនិវត្តន៍ពីថ្ងៃទី ០១-០១-២០១០**
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ					
១	**ជឹម ខួន**	ប	អគ្គនាយករង	**ក.១.៣**	**ចូលនិវត្តន៍ពីថ្ងៃទី ០១-១២-២០០៩**
ក្រសួងផែនការ					
១	**ទី ហៀង**	ប	ទីប្រឹក្សា	**ក.១.៣**	**ចូលនិវត្តន៍ពីថ្ងៃទី ០១-០៩-២០១០**

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកត.១០០១.០៦៦

លេខ: ៥៨ ច.ល
ចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១០

ស៊ុន ជិនគេន

ព្រះរាជក្រឹត្យ

នស/រកត/០១១០/០៦៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម ណារ៉ាឌី ឆាន់

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣៤៧.១០០៧.០៦៧

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១០

លេខៈ ៦១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០១១០/០៦៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

១-ឯកឧត្តម ពេជ សារឿន
២-ឯកឧត្តម អ៊ុំ សម្បូរណ៍
៣-ឯកឧត្តម យឹម សុគន្ធ
៤-លោក តេក ជា
៥-លោក គីម ស្រ៊ុន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣/ល.២០០៧.០៦៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១០

លេខៈ ៦០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១០
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

យើង

នស/រកត/០១១០/០៦៩

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

លោកឧកញ៉ា អៀង ភូតជាង

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣/ល.១០០១.០៦៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១០ លេខៈ ៥៩ ច.ល

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១០
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
ស៊ុន ចាន់ថុល

ព្រះរាជក្រឹត្យ

នស/រកត/០១១០/០៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

១- ឧត្តមសេនីយ៍ត្រី សេ សារាន់ ២- ឧត្តមសេនីយ៍ត្រី សួន វី
៣- វរសេនីយ៍ឯក នាង សារិ ៤- វរសេនីយ៍ឯក អ៊ុំ ណារី
៥- វរសេនីយ៍ឯក អេង សុភាព

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ

១- វរសេនីយ៍ទោ អ៊ុក ស៊ីថា ២- វរសេនីយ៍ទោ ឡុង អ៊ន
៣- វរសេនីយ៍ទោ ហែម សេត ៤- វរសេនីយ៍ទោ យឹម សំអូន

គ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ

១- វរសេនីយ៍ទោ ម៉ៅ ចន្ទ័ដារ៉ា ២- វរសេនីយ៍ទោ អេង ធុវ្ហា
៣- វរសេនីយ៍ត្រី ប៊្រាំ ស៊ីថា ៤- អនុសេនីយ៍ឯក នាក់ ណារ៉ូ
៥- អនុសេនីយ៍ឯក ម៉ឹង សុផាន់ណារ៉ូ ៦- អនុសេនីយ៍ទោ ប៊្រាំ សារ៉ាន់
៧- អនុសេនីយ៍ត្រី ហ៊ុន ហ៊ន ៨- ព្រិន្ទបាលឯក ពាន សុខុម

ព្រះហស្តលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

៣រ៧.២០០៦.០៧៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១០

លេខ: ៧៨ ច.ល
សម្រាប់ចម្លងចែក
ភ្នំពេញ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ២០១០
អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
ស៊ុន ជិនគេន

ព្រះរាជក្រឹត្យ

នស/រកត/០១១០/០៧៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ក-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រិយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន
ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១- ឯកឧត្តមបណ្ឌិត ចម ប្រសិទ្ធ ២- ឯកឧត្តមឧកញ៉ា ឈឹម ឌីណា
៣- ឯកឧត្តមឧកញ៉ា ជា ថុង ៤- លោក ឆួច ឆៃ

ខ-គ្រឿងឥស្សរិយយស សេនាជ័យសិទ្ធ ចំពោះ :

១- ឧត្តមសេនីយ៍ត្រី ផាន សុខេន ២- លោកវរសេនីយ៍ទោ ង៉ល់ សុធី
៣- លោកវរសេនីយ៍ឯក សុង ខេមរិន ៤- លោក ឃុត សារិនធី

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :

១-ឧត្តមសេនីយ៍ត្រី សូ ណាល់ ២-ឧត្តមសេនីយ៍ត្រី ជួង សាំងហាក់
៣- លោក ម៉ិច វី ៤- លោក គ្រួយ សេងហុង
៥- លោក ខៀវ សារ៉ុត ៦- លោក ប៉ែន ចណ្ណៈ
៧- លោកស្រី ប៊ុន ណារី ៨- លោក ឆោង បូណា
៩- លោកវរសេនីយ៍ឯក សុង រ៉ា ១០- លោក ខៀប គីរុណ
១១- លោកវរសេនីយ៍ទោ ផេង ធី ១២- លោកវរសេនីយ៍ត្រី ស្វាយ ស៊ីប៊ុណ្ណា
១៣- លោកអនុសេនីយ៍ឯក អោម មុន្នីវង្ស ១៤- លោក ប៉ុល សុភាខុន

ឃ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ ធិបឌិន្ទ ចំពោះ :

១- លោក លាង អូត ២- លោកជំទាវ ម៉ាន់ ណាទី

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :

១- លោក សោ ស៊ឹម ២- លោក ឈន ហួរ
៣- លោក អ៊ួន ធឿន ៤- លោក សេង ចេង
៥- លោក ហេង ស៊ីថុន ៦- លោក ជឹម សំអយ
៧- លោក ម៉ក់ ដារ៉េត ៨-លោកវរសេនីយ៍ត្រី ហាម ម៉ុត

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧.១០០១.០៧៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១០

លេខ: ៦៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែមករា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឈុន ម៉ឺងគេន

ព្រះរាជក្រឹត្យ

នស/រកត/០១១០/០៧៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៤ នាថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា** នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

<u>មាត្រា១</u> ៖ ត្រូវបានតែងតាំង ៖

១- ឯកឧត្តម ម៉ាន់ ម៉ុនធឿន ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

២- ឯកឧត្តម យិន សុចណ្ណ ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

៣- ឯកឧត្តម ឈី សុខា ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

<u>មាត្រា២</u> ៖ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

<u>មាត្រា៣</u> ៖ ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.១០០១.០៧៧

លេខៈ ៦៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០១០
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១០

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០១១០/០៧៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រទានព្រះរាជទាន

នូវ

ក. គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ

ឯកឧត្តមឧកញ៉ា គាំង ម៉េងហ៊ុយ

ខ. គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ

ឯកឧត្តមឧកញ៉ា គី ធីតា

គ. គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា ចំពោះ

ឯកឧត្តមឧកញ៉ា ស៊ីន គង់

ឃ. គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ

១- លោក លឹម ណាឡេង

២- លោកជំទាវ ឃុន ហៀង គាំង ម៉េងហ៊ុយ

៣- លោកជំទាវ សេង ម៉ាលីនី តែ អ៊ីឆែ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣/ល.១០០១.០៧៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១០

លេខៈ ៦៤ ច.ល

បានឃើញ និងចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ មករា ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០១១០/០៧៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/៨៦៦ ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានបញ្ចប់ភារកិច្ច ឯកឧត្តម **ហុង រដ្ឋាវុធ** ពីអគ្គលេខាធិការរង នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ។

មាត្រា២ : ត្រូវបានតែងតាំង ឯកឧត្តម **យឹម ឈាត** ជាអគ្គលេខាធិការរង នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ជំនួស ឯកឧត្តម **ហុង រដ្ឋាវុធ** ។

មាត្រា៣ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

៣៧.២០០១.០៧៩

លេខ: ៦៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០១០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១០.

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុំ ម៉ានិត ជំនកេន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៨. អនក្រ.បក

អនុក្រឹត្យ
ស្តីពី
នីតិវិធីនៃការវិនិយោគ ការដេញថ្លៃជាសាធារណៈ ឬការជួលតាមការព្រមព្រៀង និងការបង់ថ្លៃឈ្នួលនេសាទ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៦ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានជលផលទៅជារដ្ឋបាលជលផល
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៨ ខែមករា ឆ្នាំ២០១០

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១.-

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីនីតិវិធីនៃការវិនិយោគ ការដេញថ្លៃជាសាធារណៈ ឬការជួលតាមការព្រមព្រៀង និងការបង់ថ្លៃឈ្នួលនេសាទសម្រាប់ធ្វើអាជីវកម្មនេសាទ ។

មាត្រា២.-

អនុក្រឹត្យនេះមានគោលបំណងធានាតម្លាភាពក្នុងការវិនិយោគ ការដេញថ្លៃ ការជួលកន្លែងនេសាទ ការប្រមូលចំណូលថវិកា និងធានាការគ្រប់គ្រង ការប្រើប្រាស់ ការធ្វើអាជីវកម្ម និងការអភិវឌ្ឍធនធានជលផលប្រកបដោយនិរន្តរភាព ។

មាត្រា៣.-

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើដែននេសាទទឹកសាប និងដែននេសាទសមុទ្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែកន្លែងនេសាទគ្រួសារ សហគមន៍នេសាទ និងកន្លែងអភិរក្សជលផល ។

មាត្រា៤.-

វាក្យសព្ទ ដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចតទៅ ៖

ឡូត៍នេសាទ សំដៅដល់ចំណាត់ថ្នាក់នៃដែននេសាទទឹកសាបដែលផ្តល់នូវផលនេសាទ ហើយត្រូវបានកំណត់ភូមិសាស្ត្រជាក់លាក់ដែលមានប្រព័ន្ធបឹង ព្រែក ព្រៃលិចទឹក ធនធានជលផល និងជីវចម្រុះ ដែលកំណត់នូវការកកើត និងរីកធំធាត់របស់មច្ឆជាតិ វារីសត្វ និងវារីរុក្ខជាតិ ហើយនឹងត្រូវបានកំណត់នូវទីតាំង និងពេលវេលាអាជីវកម្មជាក់លាក់ ដោយមិនជះឥទ្ធិពលដល់ទីតាំងដទៃទៀត ។

ការវិនិយោគអាជីវកម្មឡូត៍នេសាទ សំដៅដល់ការវិនិយោគដោយឡែកមួយសម្រាប់ការស្តារ និងការលើកស្ទួយធនធានជលផលនៅក្នុងនាទីឡូត៍នេសាទដែលខ្សោយផលិតភាព រួមមាន ការដាំ ការថែរក្សានាទីព្រៃលិចទឹក ការស្តារឱ្យមានជម្រៅតាមប្រព័ន្ធបឹងព្រែក ក្នុងគោលបំណងបង្កើនទិន្នផល ផលត្រី ។

ភាពខ្សោយផលិតភាព សំដៅដល់ភាពទ្រុឌទ្រោម រេចរឹល ខ្សត់ខ្សោយធនធាន និងមិនផ្តល់ទិន្នផលខ្ពស់ ។

ការដេញថ្លៃ សំដៅដល់ការចូលរួម និងហ៊ានឱ្យថ្លៃខ្ពស់ជាងគេ ដោយរូបវន្តបុគ្គល ឬនីតិបុគ្គលបន្ថែមពីលើថ្លៃមូលដ្ឋានដែលសមត្ថកិច្ចជំនាញបានកំណត់រួច ។

ថ្លៃឈ្នួលឡូត៍នេសាទ សំដៅដល់ថ្លៃឈ្នួលជាមូលដ្ឋានរបស់ឡូត៍នេសាទ សម្រាប់ដាក់ដេញថ្លៃជាសាធារណៈ និងកំណត់ដាក់ឱ្យដេញថ្លៃឡើង ។

ប្រាក់ធានាសន្តាប សំដៅដល់ប្រាក់ដែលរូបវន្តបុគ្គល ឬនីតិបុគ្គលដាក់តម្កល់ទុកឱ្យសមត្ថកិច្ចជំនាញសម្រាប់ធានាការធ្វើអាជីវកម្មនេសាទ ហើយដែលប្រាក់នេះនឹងបង្វែរបង្គ្រប់ថ្លៃឈ្នួលឡូត៍នៅរដូវនេសាទបន្ទាប់ ។

រូបវន្តបុគ្គល មនុស្សពិតតាមធម្មជាតិ ដែលផ្ទុយនឹងនីតិបុគ្គល ។

នីតិបុគ្គល ក្រុមមនុស្ស ឬមូលនិធិដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ច ។

ការនេសាទជាលក្ខណៈគ្រួសារ សំដៅដល់ការនេសាទទ្រង់ទ្រាយតូចដែលប្រើប្រាស់ឧបករណ៍មានលក្ខណៈទោល ។ ការនេសាទជាលក្ខណៈគ្រួសារក៏ជាការនេសាទដែលមានលក្ខណៈជាប្រពៃណី ហើយជាទូទៅពុំមែនសម្រាប់គោលបំណងធ្វើពាណិជ្ជកម្មទេ ។

ការនេសាទជាលក្ខណៈសិប្បកម្ម សំដៅដល់ការនេសាទទ្រង់ទ្រាយមធ្យម ប្រើប្រាស់ឧបករណ៍នេសាទមានលក្ខណៈទោល ឬឧបករណ៍នេសាទមានលក្ខណៈជាបរិក្ខារ ហើយធ្វើសកម្មភាពនេសាទដោយកម្លាំងពលកម្មម្នាក់ ឬច្រើននាក់ ។ ក៏ប៉ុន្តែក្នុងការធ្វើនេសាទដោយកម្លាំងពលកម្មច្រើននាក់ក៏ដោយ ក៏សកម្មភាពនោះមិនអាចបែងចែកក្រុមដោយឡែកពីគ្នាច្បាស់លាស់ឡើយ ហើយថែមទាំងអនុវត្តសកម្មភាពក្នុងពេលព្រមគ្នា ។

ការនេសាទជាលក្ខណៈឧស្សាហកម្ម សំដៅដល់ការនេសាទទ្រង់ទ្រាយធំដែលប្រើប្រាស់ឧបករណ៍នេសាទមានលក្ខណៈជាបរិក្ខារ ហើយធ្វើសកម្មភាពនេសាទដោយប្រើប្រាស់កម្លាំងពលកម្មតាមក្រុមដាច់ដោយឡែកពីគ្នា ហើយក្រុមនីមួយៗអាចប្រើពេលវេលាពលកម្មខុសគ្នា ។

ជំពូកទី២
គោលការណ៍នៃការធ្វើអាជីវកម្មឡូត៍នេសាទ

មាត្រា៥.-

ការធ្វើអាជីវកម្មឡូត៍នេសាទ ត្រូវមានអ្នកជំនាញបច្ចេកទេសនេសាទម្នាក់ដែលមានសញ្ញាបត្រមធ្យមជលផលឡើងទៅ ដើម្បីធ្វើគម្រោងផែនការគ្រប់គ្រងការធ្វើអាជីវកម្មឡូត៍នេសាទ ចូលរួមអភិរក្សធនធានជលផល តាមដានអង្កេត ប្រមូលទិន្នន័យ និងធ្វើរបាយការណ៍បូកសរុបលទ្ធផល នៅចុងបញ្ចប់រដូវនេសាទនីមួយៗ ។

មាត្រា៦.-

អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទអាចផ្ទេរសិទ្ធិកាន់កាប់ឡូត៍នេសាទឱ្យសហពទ្ធ ឬកូន ឬតំណាងស្របច្បាប់ ដើម្បីទទួលខុសត្រូវជំនួស ដោយមានការយល់ព្រមពីរដ្ឋបាលជលផលថ្នាក់កណ្តាល ។ ក្នុងករណីដែលអ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទនោះទទួលមរណភាព ឬបាត់បង់សមត្ថភាព ដោយមានការបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច រដ្ឋបាលជលផលត្រូវរៀបចំសំណុំបែបបទដើម្បីផ្ទេរទៅឱ្យសហពទ្ធ ឬកូន ឬតំណាងស្របច្បាប់ទទួលខុសត្រូវជំនួសតាមការស្នើសុំ ។

មាត្រា៧.-

ការធ្វើអាជីវកម្មឡូត៍នេសាទអាចប្រព្រឹត្តទៅបាន លុះត្រាតែមានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មឡូត៍នេសាទ និងត្រូវគោរពដាច់ខាតតាមសៀវភៅបន្ទុកឡូត៍នេសាទ ។

គំរូសៀវភៅបន្ទុកឡូត៍នេសាទដែលបានរៀបចំឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា៨.-

អ្នកដែលទទួលបានសិទ្ធិកាន់កាប់ឡូត៍នេសាទ មិនអាចយកឡូត៍នេសាទទាំងមូល ឬផ្នែកណាមួយនៃឡូត៍នេសាទ ដែលបានទទួលសិទ្ធិកាន់កាប់ ទៅជូលឱ្យអ្នកដទៃឡើយ ។ ក្នុងករណីមានការរំលោភបទប្បញ្ញត្តិនេះ ត្រូវនិរាករណ៍សិទ្ធិនៃការកាន់កាប់ឡូត៍នេសាទនោះ ។

ជំពូកទី៣
នីតិវិធីនៃការវិនិយោគអាជីវកម្មឡូត៍នេសាទ

មាត្រា៩.-

រដ្ឋបាលជលផលថ្នាក់កណ្តាល ត្រូវសិក្សាពីចំនួនឡូត៍នេសាទដែលខ្សោយផលិតភាព និងត្រូវកសាងផែនការវិនិយោគតាមឡូត៍នេសាទនីមួយៗ ដាក់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីស្នើសុំការអនុញ្ញាតពីរាជរដ្ឋាភិបាលសម្រេចមុនពេលដាក់ឱ្យវិនិយោគ ។

មាត្រា១០.-

ក្រោយពេលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាល រដ្ឋបាលជលផលត្រូវធ្វើសេចក្តីជូនដំណឹងអំពីការដេញថ្លៃជាសាធារណៈ និងបិទផ្សាយនៅរដ្ឋបាលជលផលថ្នាក់កណ្តាល ខណ្ឌរដ្ឋបាលជលផល សាលារាជធានី ខេត្ត ឱ្យបានយ៉ាងតិច ៣០(សាមសិប)ថ្ងៃ មុនពេលបើកសំបុត្រដេញថ្លៃវិនិយោគ ។

មាត្រា១១.-

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងវិនិយោគអាជីវកម្មឡូត៍នេសាទ ត្រូវធ្វើពាក្យសុំមករដ្ឋបាលជលផល តាមរយៈខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផលសាមី ដោយបញ្ជាក់គម្រោងផែនការវិនិយោគ ទុនវិនិយោគក្នុងក្របខណ្ឌអភិវឌ្ឍធនធានជលផល ។ រយៈពេលនៃការវិនិយោគអាជីវកម្មឡូត៍នេសាទ ត្រូវគោរពតាមផែនការវិនិយោគឡូត៍នេសាទនីមួយៗដែលសម្រេចដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ទុនវិនិយោគសម្រាប់ធ្វើការអភិវឌ្ឍ និងកែលំអ មិនរាប់បញ្ចូលថ្លៃឈ្នួលឡូត៍នេសាទដែលត្រូវបង់ជូនរដ្ឋឡើយ ។

មាត្រា១២.-

ការស្នើសុំវិនិយោគអាជីវកម្មឡូត៍នេសាទ ត្រូវមានសំណុំលិខិតភ្ជាប់មកជាមួយដូចខាងក្រោម ៖

ក. ចំពោះរូបវន្តបុគ្គល ៖

១- ពាក្យស្នើសុំវិនិយោគអាជីវកម្មឡូត៍នេសាទមានបិទតែមប្រិ៍សារពើពន្ធ និងបិទរូបថត (៤ x ៦) ចំនួន០៣ ច្បាប់

២- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងបណ្ណគ្រួសារថតចម្លងដោយមានការបញ្ជាក់ពីមេឃុំ ឬចៅសង្កាត់ ចំនួន០៣ ច្បាប់

៣- លិខិតបញ្ជាក់សមត្ថភាពជំនាញខាងធ្វើអាជីវកម្មឡូត៍នេសាទចេញដោយរដ្ឋបាលជលផលតាមរយៈខណ្ឌរដ្ឋបាលជលផលដែលសាមីជនរស់នៅ ចំនួន០៣ ច្បាប់

៤- គម្រោងផែនការស្នើសុំវិនិយោគដាក់ក្នុងស្រោមសំបុត្របិទជិត ចំនួន០៣ ច្បាប់

៥- កិច្ចសន្យាវិនិយោគឡូត៍នេសាទ ចំនួន០៣ ច្បាប់

៦- ប្រកាសឥណទានរបស់ធនាគារអំពីប្រាក់ធានាបណ្តោះអាសន្ន ១/៣ (មួយភាគបី) នៃថ្លៃព្យូរឡូត៍នេសាទ ចំនួន០៣ ច្បាប់

៧- កិច្ចសន្យាប្រគល់ប្រាក់ធានាស្ថាពរ៥០(ហាសិប) ភាគរយ នៃថ្លៃដែលដេញបាន ចំនួន០៣ ច្បាប់

៨- កិច្ចសន្យាស្តីពីការគោរពឱ្យបានត្រឹមត្រូវតាមសៀវភៅបន្ទុក និង លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មឡូត៍នេសាទ ចំនួន០៣ ច្បាប់ ។

ខ. ចំពោះនីតិបុគ្គលត្រូវភ្ជាប់បន្ថែម ៖

១- លិខិតប្រគល់សិទ្ធិជាតំណាងស្របច្បាប់ ចំនួន ០៣ ច្បាប់

២- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មចេញដោយ ក្រសួងពាណិជ្ជកម្ម ចំនួន ០៣ ច្បាប់

៣- លក្ខន្តិកៈក្រុមហ៊ុនមាននីត្យានុកូលភាព ចំនួន ០៣ ច្បាប់

៤- បណ្ណប៉ាតង់ ចំនួន ០៣ ច្បាប់ ។

មាត្រា១៣.-

មិនអនុញ្ញាត ឬមិនទទួលពាក្យស្នើសុំវិនិយោគអាជីវកម្មឡូត៍នេសាទចំពោះ ៖

- មន្ត្រីរាជការ
- រូបវន្តបុគ្គល ឬនីតិបុគ្គលណាដែលកន្លងមកមិនបានអនុវត្តតាមកិច្ចសន្យាវិនិយោគ ឬធ្លាប់បានប្រព្រឹត្តបទល្មើសនេសាទមានលក្ខណៈធ្ងន់ធ្ងរ ឬនៅជំពាក់ថ្លៃឈ្នួលឡូត៍នេសាទ ឬប្រាក់បំណុលរដ្ឋផ្សេងៗ ។

មាត្រា១៤.-

ការប្រគល់ឡូត៍នេសាទឱ្យធ្វើការវិនិយោគ ត្រូវស្ថិតនៅក្រោមការចាត់ចែងរបស់គណៈកម្មការវិនិយោគឡូត៍នេសាទ ដែលមានសមាសភាពដូចខាងក្រោម ៖

- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬតំណាង ប្រធាន
- ប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល ឬតំណាង អនុប្រធាន
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬតំណាង សមាជិក
- ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬតំណាង សមាជិក
- ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬតំណាង សមាជិក
- នាយអធិការដ្ឋានរដ្ឋបាលជលផលសាមី ឬតំណាង សមាជិក
- នាយខណ្ឌរដ្ឋបាលជលផលសាមី ឬតំណាង សមាជិក
- ប្រធាននាយកដ្ឋានកិច្ចការជលផល

សមាសភាពជាក់ស្តែងនៃគណៈកម្មការវិនិយោគឡូត៍នេសាទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា១៥.-

គណៈកម្មការវិនិយោគឡូត៍នេសាទត្រូវពិនិត្យ និងធ្វើការវាយតម្លៃលើចរិតលក្ខណៈបច្ចេកទេសអាជីវកម្មនេសាទ ហើយកំណត់ចំនួនឯកសារវិនិយោគបានការ ព្រមទាំងកំណត់ពេលបើកស្រោមសំបុត្រសម្រេច។

បន្ទាប់ពីបានអនុវត្តចប់សព្វគ្រប់តាមនីតិវិធីនៃការស្នើសុំវិនិយោគ និងក្រោយពីទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចេញសេចក្ដីសម្រេចប្រគល់សិទ្ធិកាន់កាប់ឡូត៍នេសាទឱ្យធ្វើការវិនិយោគ។

មាត្រា១៦.-

វិនិយោគិនដែលទទួលបានសិទ្ធិវិនិយោគ ត្រូវធ្វើគម្រោងផែនការវិនិយោគអាជីវកម្មឡូត៍នេសាទ ដែលទទួលបានការឯកភាពពីរដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជូនអាជ្ញាធរមានសមត្ថកិច្ច ដើម្បីបញ្ចូលក្នុងផែនការសកម្មភាពអភិវឌ្ឍមូលដ្ឋាន។

ជំពូកទី៤
នីតិវិធីនៃការដេញថ្លៃឡូត៍នេសាទ

មាត្រា១៧.-

ដើម្បីដេញថ្លៃឡូត៍នេសាទ រដ្ឋបាលជលផលត្រូវធ្វើសេចក្ដីជូនដំណឹងអំពីការដេញថ្លៃជាសាធារណៈ និងបិទផ្សាយនៅរដ្ឋបាលជលផលថ្នាក់កណ្ដាល ខណ្ឌរដ្ឋបាលជលផល សាលារាជធានី ខេត្ត ឱ្យបានយ៉ាងតិច៣០(សាមសិប)ថ្ងៃ មុនពេលដេញថ្លៃ ហើយត្រូវបញ្ជាក់អំពី ៖

- ទីតាំងឡូត៍នេសាទដែលត្រូវដាក់ឱ្យដេញថ្លៃ
- ថ្លៃព្យួរឡូត៍នេសាទក្រោយពីបានពិគ្រោះយោបល់ជាមួយតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ប្រាក់ធានាបណ្ដោះអាសន្ន
- ទីកន្លែង និងពេលវេលាដែលត្រូវដេញថ្លៃ។

មាត្រា១៨.-

ការដេញថ្លៃឡូត៍នេសាទ ត្រូវប្រព្រឹត្តទៅនៅសាលារាជធានី ខេត្ត ហើយស្ថិតនៅក្រោមការចាត់ចែងរបស់គណៈកម្មការដេញថ្លៃឡូត៍នេសាទដែលមានសមាសភាពដូចខាងក្រោម ៖

- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬតំណាង ប្រធាន
- ប្រធានរដ្ឋបាលជលផលថ្នាក់កណ្ដាល ឬតំណាង អនុប្រធាន
- តំណាងប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬតំណាង សមាជិក
- ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ឬតំណាង សមាជិក
- នាយអធិការដ្ឋានរដ្ឋបាលជលផល ឬតំណាង សមាជិក

- ប្រធាននាយកដ្ឋានកិច្ចការជលផល សមាជិក
- នាយខណ្ឌ ឬនាយរងខណ្ឌរដ្ឋបាលជលផល សមាជិក និងជាលេខាធិការ ។

សមាសភាពជាក់ស្តែងនៃគណៈកម្មការដេញថ្លៃឡូត៍នេសាទ ត្រូវកំណត់ដោយដីការបស់រាជធានី ខេត្ត ។

មាត្រា១៩.-

រូបវន្តបុគ្គល ឬនីតិបុគ្គលណាដែលមានប្រាក់ទុន មធ្យោបាយ និងជំនាញខាងធ្វើអាជីវកម្មឡូត៍នេសាទ ហើយដែលមិនត្រូវបានប្រាសចាកសិទ្ធិដូចមានចែងក្នុងមាត្រា២១នៃអនុក្រឹត្យនេះ មានសិទ្ធិចូលដេញថ្លៃឡូត៍នេសាទបាននៅតាមបណ្តារាជធានី ខេត្ត ។

មាត្រា២០.-

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងចូលដេញថ្លៃ ត្រូវដាក់ពាក្យសុំដេញថ្លៃធ្វើអាជីវកម្មឡូត៍នេសាទយ៉ាងយូរបំផុត១០(ដប់)ថ្ងៃ មុនពេលដេញថ្លៃ នៅខណ្ឌរដ្ឋបាលជលផលដែលមានឡូត៍នេសាទដាក់ឱ្យដេញថ្លៃ ។

ពាក្យសុំដេញថ្លៃខាងលើនេះ ត្រូវមានសំណុំលិខិតភ្ជាប់មកជាមួយដូចខាងក្រោម ៖

ក. ចំពោះរូបវន្តបុគ្គល ៖

១- ពាក្យសុំចូលដេញថ្លៃឡូត៍នេសាទទីមួយៗ ដែលមានបិទតែមប្រើសារពើពន្ធ ចំនួន ០៣ ច្បាប់

២- រូបថត ៤ x ៦ ចំនួន ០៣ សន្លឹក

៣- ឯកសារដូចមានក្នុងចំណុច ២ ៣ ៦ ៧ និង៨ កថាខណ្ឌ ក មាត្រា១២ នៃអនុក្រឹត្យនេះ ។

ខ. ចំពោះនីតិបុគ្គល ត្រូវភ្ជាប់បន្ថែមដូចចំណុច ខ មាត្រា១២ នៃអនុក្រឹត្យនេះ ។

មាត្រា២១.-

មិនអនុញ្ញាតឱ្យចូលដេញថ្លៃឡូត៍នេសាទចំពោះ ៖

- មន្ត្រីរាជការ
- រូបវន្តបុគ្គល ឬនីតិបុគ្គលណាដែលធ្លាប់ដេញថ្លៃបានហើយមិនគោរពកិច្ចសន្យា ធ្លាប់បានប្រព្រឹត្តបទល្មើសនេសាទមានលក្ខណៈធ្ងន់ធ្ងរ ឬនៅជំពាក់ថ្លៃឈ្នួលឡូត៍នេសាទ ឬប្រាក់បំណុលរដ្ឋផ្សេងៗ ។

មាត្រា២២.-

ការដេញថ្លៃឡូត៍នេសាទមួយលើកៗ ត្រូវបានកំណត់សម្រាប់ឱ្យធ្វើអាជីវកម្មនេសាទក្នុងរយៈពេលពីររដូវនេសាទជាប់គ្នា ។

មាត្រា២៣.-

នីតិវិធីនៃការដេញថ្លៃត្រូវអនុវត្តដូចខាងក្រោម ៖

នៅពេលចាប់ផ្តើមការដេញថ្លៃឡូត៍នេសាទទីមួយៗ គណៈកម្មការដេញថ្លៃឡូត៍នេសាទ ត្រូវប្រកាសឈ្មោះអ្នកមានសិទ្ធិចូលដេញថ្លៃ ទីតាំងឡូត៍នេសាទ និងថ្លៃឈ្នួលឡូត៍នេសាទដែលកំណត់ដាក់ឱ្យដេញថ្លៃ ព្រមទាំងអានសៀវភៅបន្ទុកឡូត៍នេសាទ ។

នីតិវិធីនៃការដេញថ្លៃ ត្រូវអនុវត្តតាមរូបភាពដេញថ្លៃឡើង ដោយដាក់ក្នុងស្រោមសំបុត្របិទជិត...

-លើកទី ១ : ត្រូវដេញថ្លៃខ្ពស់ជាងថ្លៃកំណត់ដាក់ឱ្យដេញថ្លៃ ។ អ្នកដែលដាក់ថ្លៃទាបជាង... គ្មានសិទ្ធិចូលដេញថ្លៃនៅលើកទី២ទៀតបានទេ ។

-លើកទី ២ : ត្រូវដេញថ្លៃបន្ត ចាប់ពីថ្លៃដែលខ្ពស់ជាងគេនៅលើកទី១។ អ្នកដែលដាក់ថ្លៃទាបជាងនេះ ពុំមានសិទ្ធិចូលដេញថ្លៃនៅលើកទី៣ទៀតបានឡើយ។

-លើកទី ៣ : ត្រូវដេញថ្លៃបន្ត ចាប់ពីថ្លៃខ្ពស់ជាងគេនៅលើកទី២ ហើយអ្នកដែលហ៊ានឱ្យថ្លៃខ្ពស់ជាងគេ ត្រូវបានប្រកាសទទួលស្គាល់ថាជាអ្នកដេញថ្លៃបានជាបណ្តោះអាសន្ន។

ក្នុងករណីដែលទឹកប្រាក់ដេញថ្លៃខ្ពស់ជាងគេនៅលើកទី៣នេះស្មើគ្នាចាប់ពី០២នាក់ឡើងទៅ គណៈកម្មការដេញថ្លៃឡូត៍នេសាទ ត្រូវរៀបចំធ្វើការដេញថ្លៃតាមនីតិវិធីខាងលើជាបន្តរហូតនៅសល់តែអ្នកហ៊ានឱ្យថ្លៃខ្ពស់ជាងគេតែម្នាក់។ គណៈកម្មការដេញថ្លៃឡូត៍នេសាទត្រូវប្រកាសនិងបង្ហាញជាសាធារណៈនូវលទ្ធផលនៃការដេញថ្លៃរាល់ពេលបើកស្រោមសំបុត្រដេញថ្លៃមួយលើកៗ។

មាត្រា២៤.-

ក្នុងករណីដែលមានអ្នកចូលដេញថ្លៃមានតែម្នាក់ គណៈកម្មការដេញថ្លៃឡូត៍នេសាទមានសិទ្ធិចរចាពិគ្រោះថ្លៃជាមួយនឹងអ្នកចូលដេញថ្លៃដោយត្រូវមានថ្លៃលើសពីថ្លៃព្យូរឡូត៍នេសាទ។

នៅពេលដេញថ្លៃ បើមានឡូត៍នេសាទខ្លះដែលគ្មានអ្នកដាក់ពាក្យចូលដេញថ្លៃ គណៈកម្មការដេញថ្លៃឡូត៍នេសាទត្រូវកំណត់ថ្លៃព្យូរឡូត៍នេសាទម្តងទៀតជាលើកចុងក្រោយឱ្យបានសមស្រប និងកំណត់ពេលវេលាត្រឹម១៥(ដប់ប្រាំ)ថ្ងៃក្រោយពេលប្រកាសជូនដំណឹង។

មាត្រា២៥.-

រាល់ការដេញថ្លៃបាន ត្រូវចាត់ទុកជាមោឃៈ ក្នុងករណីណាមួយដូចខាងក្រោម ៖

១- ការដេញថ្លៃឡូត៍នេសាទដោយមិនបានធ្វើសេចក្តីជូនដំណឹង ដូចមានចែងក្នុងមាត្រា១៧ ឬដេញថ្លៃខុសពីសេចក្តីបញ្ជាក់ក្នុងសេចក្តីជូនដំណឹង។

២- មានភស្តុតាងបញ្ជាក់ថា អ្នកដេញថ្លៃបាននោះ បានឃុបឃិតជាមួយអ្នកដទៃទៀត ឬមានកលល្បិចធ្វើឱ្យការដេញថ្លៃនោះមានតម្លៃថោក ចាប់ពីពេលដេញថ្លៃរហូតដល់មុនពេលចេញសេចក្តីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៣- អ្នកដេញថ្លៃបានហើយនោះ មិនបានបង់ប្រាក់ធានាស្ថាពរនៃថ្លៃដេញបានឱ្យបានគ្រប់ចំនួន៥០(ហាសិប)ភាគរយ ក្រោយពេលដេញថ្លៃ១៥(ដប់ប្រាំ)ថ្ងៃ។

ក្នុងករណីណាមួយខាងលើនេះកើតមានឡើង គណៈកម្មការដេញថ្លៃឡូត៍នេសាទ ត្រូវរៀបចំដេញថ្លៃឡូត៍នេសាទនោះសាជាថ្មី ក្រោយពីបានធ្វើសេចក្តីជូនដំណឹងចំនួន១៥(ដប់ប្រាំ)ថ្ងៃរួចមក។

រូបវន្តបុគ្គល ឬនីតិបុគ្គលណាដែលមានបំណងដេញថ្លៃ ត្រូវដាក់សំណុំបែបបទសុំចូលដេញថ្លៃយ៉ាងយូរបំផុតឱ្យបាន ២(ពីរ)ថ្ងៃ មុនពេលដេញថ្លៃ។

មាត្រា២៦.-

ក្នុងករណីដែលអ្នកមានឈ្មោះចូលដេញថ្លៃអវត្តមានដោយមូលហេតុចាំបាច់ណាមួយ ត្រូវប្រគល់សិទ្ធិឱ្យតំណាងរបស់ខ្លួនម្នាក់ចូលដេញថ្លៃជំនួស ប៉ុន្តែលិខិតប្រគល់សិទ្ធិត្រូវមានការបញ្ជាក់ពីមេឃុំ ឬចៅសង្កាត់ ឬមេធាវី ឬសារការី ។ លិខិតប្រគល់សិទ្ធិត្រូវបង្ហាញជូនគណៈកម្មការដេញថ្លៃឡូត៍នេសាទ មុនពេលដេញថ្លៃ។

មាត្រា២៧.-

អ្នកដែលត្រូវបានប្រកាសទទួលស្គាល់ថាជាអ្នកដេញថ្លៃបានជាបណ្តោះអាសន្ន ត្រូវបង់ប្រាក់ធានាស្ថាពរដោយគិតរួមទាំងប្រាក់ធានាបណ្តោះអាសន្នផង ឱ្យបានគ្រប់ចំនួន៥០(ហាសិប)ភាគរយនៃថ្លៃឈ្នួលឡូត៍នេសាទដេញថ្លៃបានយ៉ាងយូរបំផុតរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ក្រោយពេលដេញថ្លៃ។

ប្រាក់ធានាស្ថាពរ គឺសម្រាប់ធានាការគោរពកិច្ចសន្យា ហើយត្រូវបានរក្សាទុកសម្រាប់បង់ថ្លៃឈ្នួលឡូត៍នេសាទបង្គ្រប់នៅចុងរដូវនេសាទទី២។

មាត្រា២៨.-

ខណ្ឌរដ្ឋបាលជលផលសាមី ត្រូវរៀបចំគ្រប់សំណុំលិខិតអ្នកដេញថ្លៃបានជាបណ្តោះអាសន្ន និងកំណត់ហេតុនៃការដេញថ្លៃឡូត៍នេសាទ ព្រមទាំងបង្កាន់ដៃបង់ប្រាក់ធានាស្ថាពរ ហើយបញ្ជូនទៅរដ្ឋបាលជលផលថ្នាក់កណ្តាលជាបន្ទាន់ ដើម្បីពិនិត្យ និងស្នើសុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចេញសេចក្តីសម្រេចទទួលស្គាល់ថាជាអ្នកដេញថ្លៃបានជាស្ថាពរក្នុងរយៈពេលយ៉ាងយូរបំផុតត្រឹម៤៥(សែសិបប្រាំ)ថ្ងៃ ក្រោយពេលដេញថ្លៃបាន។ ក្រោយពីមានសេចក្តីសម្រេចនេះ រដ្ឋបាលជលផលថ្នាក់កណ្តាលត្រូវចេញលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មឡូត៍នេសាទ ឱ្យដល់អ្នកដែលដេញថ្លៃបានយ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃ។

មាត្រា២៩.-

គណៈកម្មការដេញថ្លៃឡូត៍នេសាទ ត្រូវចេញលិខិតបញ្ជាក់ជូនអ្នកដេញថ្លៃពុំបាន ដើម្បីយកទៅដកប្រាក់តក់ធានាបណ្តោះអាសន្នរបស់ខ្លួនវិញ។

មាត្រា៣០.-

អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទ ត្រូវបង់ថ្លៃឈ្នួលឡូត៍នេសាទ នៅរតនាគាររាជធានី ខេត្តសាមី តាមពេលវេលាកំណត់ក្នុងសៀវភៅបន្ទុកឡូត៍នេសាទ។ ក្រោយពេលបង់ប្រាក់ថ្លៃឈ្នួលឡូត៍នេសាទ អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទត្រូវយកបង្កាន់ដៃបង់ប្រាក់មកតម្កល់ទុកនៅខណ្ឌរដ្ឋបាលជលផលសាមីសម្រាប់ផ្ទៀងផ្ទាត់។

មាត្រា៣១.-

ថ្លៃឈ្នួលឡូត៍នេសាទដេញថ្លៃបាន ឬថ្លៃជួលឡូត៍នេសាទតាមថ្លៃព្រមព្រៀង គឺជាថ្លៃឈ្នួលឡូត៍នេសាទសុទ្ធសាធសម្រាប់ធ្វើអាជីវកម្មនេសាទក្នុងមួយរដូវនេសាទ។ នៅរដូវនេសាទទី២ ក៏ត្រូវបង់ប្រាក់ថ្លៃឈ្នួលឡូត៍នេសាទ ដូចរដូវនេសាទទី១ដែរ។

អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទត្រូវបង់ពន្ធប៉ាតង់ និងបង់ពន្ធអាករជូនអង្គភាពពន្ធដារ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

មាត្រា៣២.-

ក្នុងករណីអ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទ មិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងសៀវភៅបន្ទុក រដ្ឋបាលជលផលត្រូវដកហូតសិទ្ធិនេះមកវិញ ហើយត្រូវរៀបចំដេញថ្លៃសាជាថ្មី តាមនីតិវិធីដែលមានចែងក្នុងមាត្រា ១៧ នៃអនុក្រឹត្យនេះ។

ក្នុងអំឡុងមុនពេលធ្វើអាជីវកម្មឡូត៍នេសាទ ក៏ដូចជាក្នុងករណីឡូត៍នេសាទត្រូវផ្អាកបង់ថ្លៃឈ្នួល ខណ្ឌរដ្ឋបាលជលផលសាមី ត្រូវទទួលបន្ទុកការពារឡូត៍នេសាទនោះ ដើម្បីរង់ចាំការសម្រេចជាថ្មីពីរដ្ឋបាលជលផល។

ជំពូកទី៥

នីតិវិធីនៃការជួលឡូត៍នេសាទតាមការព្រមព្រៀង

មាត្រា៣៣.-

ការជួលឡូត៍នេសាទណាមួយតាមការព្រមព្រៀងអាចប្រព្រឹត្តទៅបាន លុះត្រាតែឡូត៍នេសាទនោះមិនមានអតិថិជនដាក់ពាក្យចូលរួមដេញថ្លៃ ក្រោយពេលធ្វើសេចក្តីជូនដំណឹងដូចមានចែងក្នុងមាត្រា១៧ ចំនួន២(ពីរ)លើករួចមក។ ករណីនេះក៏អាចអនុវត្តបាន ចំពោះឡូត៍នេសាទណាដែលអាជីវករនេសាទបោះបង់ចោល ក្នុងពេលកំពុងធ្វើអាជីវកម្មនេសាទដោយគ្មានមូលហេតុ។

ក្នុងករណីគ្មានអ្នកសុំជួលតាមការព្រមព្រៀង ឡូត៍នេសាទនោះត្រូវស្ថិតក្នុងការគ្រប់គ្រងរបស់រដ្ឋបាលជលផល។

មាត្រា៣៤.-

រដ្ឋបាលជលផលត្រូវប្រកាសដាក់ជួលឡូត៍នេសាទជាសាធារណៈ និងកំណត់ថ្លៃឈ្នួលឡូត៍នេសាទតាមការព្រមព្រៀង។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលបានសិទ្ធិជួលឡូត៍នេសាទតាមការព្រមព្រៀង ត្រូវគោរព និងអនុវត្តតាមបណ្តាចំណុច ២ ៣ ៦ ៧ និង៨ ចំពោះរូបវន្តបុគ្គល និងអនុវត្តបន្ថែមចំណុច ១ ២ ៣ ៤ ចំពោះនីតិបុគ្គល ស្របតាមមាត្រា១២នៃអនុក្រឹត្យនេះ។

មាត្រា៣៥.-

ក្រោយពេលទទួលបានការឯកភាពជួលឡូត៍នេសាទពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមសំណើរដ្ឋបាលជលផលរួចហើយ អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទត្រូវគោរព និងអនុវត្តតាមមាត្រា៣០ និងមាត្រា៣១នៃអនុក្រឹត្យនេះ។

ជំពូកទី៦

ការបង់ថ្លៃឈ្នួលនេសាទ

មាត្រា៣៦.-

ការធ្វើអាជីវកម្មនេសាទដោយប្រើឧបករណ៍នេសាទសិប្បកម្មក្នុងកន្លែងនេសាទបម្រុងនៃដែននេសាទទឹកសាប ឬការធ្វើអាជីវកម្មនេសាទគ្រប់ប្រភេទក្នុងដែននេសាទសមុទ្រ ត្រូវមានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម និងត្រូវបង់ថ្លៃឈ្នួលនេសាទ និងប្រាក់ពន្ធផ្សេងៗដែលពាក់ព័ន្ធ លើកលែងតែការធ្វើនេសាទជាលក្ខណៈគ្រួសារ។

មាត្រា៣៧.-

ថ្លៃឈ្នួលនេសាទលើឧបករណ៍នេសាទសិប្បកម្មក្នុងកន្លែងនេសាទបម្រុងនៃដែននេសាទទឹកសាប និងថ្លៃឈ្នួលនេសាទលើឧបករណ៍នេសាទក្នុងដែននេសាទសមុទ្រ ដែលត្រូវបានគណនាតាមប្រភេទ ទំហំ ឬចំនួនឧបករណ៍ សម្ភារៈនេសាទ ឬកម្លាំងសេះនៃម៉ាស៊ីនធ្យោបាយនេសាទ ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ទម្រង់បែបបទនៃការដាក់ពាក្យស្នើសុំធ្វើអាជីវកម្មនេសាទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

មាត្រា៣៨.-

ចំពោះជនបរទេសដែលទទួលបានការឯកភាពជាគោលការណ៍ពីរាជរដ្ឋាភិបាលឱ្យធ្វើអាជីវកម្មនេសាទហើយនោះ ការគិតយកថ្លៃឈ្នួលដែននេសាទសមុទ្រ និងបណ្តាលក្ខខណ្ឌផ្សេងៗទៀត ត្រូវកំណត់តាមការព្រមព្រៀងក្នុងកិច្ចសន្យារវាងរដ្ឋបាលជលផលថ្នាក់កណ្តាល និងភាគីបរទេស ដោយមានការឯកភាពពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ជំពូកទី៧

ចណ្ណកម្ម

មាត្រា៣៩.-

ប្រាក់ធានាបណ្តោះអាសន្នត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ក្នុងករណីណាមួយដូចខាងក្រោម ៖

- អ្នកមានឈ្មោះចូលដេញថ្លៃឡូត៍នេសាទ អវត្តមានដោយគ្មានមូលហេតុ
- នៅពេលដេញថ្លៃឡូត៍នេសាទបាន អ្នកដេញថ្លៃបានមិនព្រមផ្តិតស្នាមមេដៃលើកំណត់ហេតុដេញថ្លៃ
- ករណីដូចមានចែងក្នុងចំណុច ២ និង ៣ មាត្រា២៥នៃអនុក្រឹត្យនេះ។

មាត្រា៤០.-

ប្រាក់ធានាស្ថាពរត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ក្នុងករណីដែលអ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទ ៖

- បោះបង់ឡូត៍នេសាទចោល មុនពេលបញ្ចប់រដូវនេសាទទី២
- មិនព្រមគោរពឱ្យបានត្រឹមត្រូវតាមសៀវភៅបន្ទុកឡូត៍នេសាទ និងតាមបទបញ្ជាក្នុងលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មឡូត៍នេសាទ
- ដូចមាត្រា៨នៃអនុក្រឹត្យនេះ។

ជំពូកទី៨

អន្តរប្បញ្ញត្តិ

មាត្រា៤១.-

ក្រៅពីឡូត៍នេសាទដែលត្រូវបានកំណត់ដាក់ឱ្យវិនិយោគ ឱ្យដេញថ្លៃជាសាធារណៈ ឱ្យជួលតាមការព្រមព្រៀង ឡូត៍នេសាទទាំងឡាយណាដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលរួចហើយ ត្រូវមានសុពលភាពរហូតដល់ចប់រយៈពេលនៃការប្រគល់សិទ្ធិឱ្យធ្វើអាជីវកម្មនេសាទ ស្របតាមការសម្រេចរបស់រាជរដ្ឋាភិបាល។

ជំពូកទី៩
អវសានប្បញ្ញត្តិ

មាត្រា៤២.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៤៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងគ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដែលមានដែននេសាទ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៣៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៩.០៥៩ ហិកតា ក្នុងដែនជម្រកសត្វព្រៃភ្នំឱរាល់ ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកឱរាល់ ខេត្តកំពង់ស្ពឺ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ០៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

បើរោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា១:–

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៩.០៥៩ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំឱរាល់ ស្ថិតក្នុងភូមិសាស្ត្រស្រុកឱរាល់ ខេត្តកំពង់ស្ពឺ ក្រោមល័ក្ខខ័ណ្ឌ ជួល ឬ សម្បទាន ដើម្បីធ្វើការវិនិយោគ អភិវឌ្ឍន៍លើវិស័យដាំដំណាំកសិ-ឧស្សាហកម្ម ដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ១៦៦៩សជណ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ របស់ ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា២:–

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័ន ពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

មាត្រា៣:–

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤–

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័ន និងអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

Great Field (Cambodia) International Limited



ID	N	Coor_X	Coor_Y
1	A	374987	1293400
2	B	376457	1293150
3	C	376722	1291500
4	D	375392	1291105
5	E	376100	1290000
6	F	382730	1290000
7	G	386907	1293077
8	H	392000	1295000
9	I	392000	1301400
10	J	384525	1301300
11	K	384500	1300000
12	L	386380	1299750
13	M	386390	1297900
14	N	382770	1298000
15	O	383750	1296000
16	P	384907	1293670
17	Q	384827	1293340
18	R	380069	1293270
19	S	380050	1294000
20	T	374990	1294000

ប្រាក់_សុខុន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧០ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៩.៣៨៥ ហិកតា ក្នុងដែនជម្រកសត្វព្រៃបឹងពែរ ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំសាគ្រាម ស្រុកប្រាសាទបាល្ល័ង្ក និងស្រុកស្ទោង ខេត្តកំពង់ធំ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៥ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងប្បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២២៣ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០០៩ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រេ ច

មាត្រា១:-

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៤.៣៨៥ហិកតា ក្នុងដែនជម្រកសត្វព្រៃបឹងពែរ ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំសាគ្រាម ស្រុកប្រាសាទបាល័ង្គ និងស្រុកស្ទោង ខេត្តកំពង់ធំ ក្រោមល័ក្ខខ័ណ្ឌ ជួល ឬ សម្បទាន ដើម្បីធ្វើការវិនិយោគ អភិវឌ្ឍន៍លើវិស័យដាំដំណាំកសិ-ឧស្សាហកម្ម ដូចមានក្នុងផែនទី និង និយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ១៥៥៨ សជណ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា២:-

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័ន ពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

មាត្រា៣:-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័ន និងអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ



Id	N	Coor X	Coor Y
1	A	468000	1456740
2	B	465120	1456740
3	C	465120	1458000
4	D	465650	1458000
5	E	465650	1464000
6	F	472900	1464000
7	G	472900	1457460
8	H	468000	1457460

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧១ . អនក្រ . បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៨.៥៩១ ហិកតា ក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និង បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ០៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រេ ច

មាត្រា១:-

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៨.៥៩១ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំឱរាល់ ស្ថិតក្នុងភូមិសាស្ត្រស្រុកឱរាល់ ខេត្តកំពង់ស្ពឺ ក្រោមល័ក្ខខ័ណ្ឌ ជួល ឬ សម្បទាន ដើម្បីធ្វើការវិនិយោគ អភិវឌ្ឍន៍លើវិស័យដាំដំណាំកសិ-ឧស្សាហកម្ម ដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ១៦៧០សជណ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ របស់ ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា២:-

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយ ក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័ន ពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

មាត្រា៣:-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័ន និងអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

ផែនទីទីតាំងដីវិនិយោគ អភិវឌ្ឍន៍លើដំណាំកសិ-ឧស្សាហកម្ម របស់ក្រុមហ៊ុន Yellow Field (Cambodia) International Limited
ស្ថិតនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព នៃដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ឃុំ... ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ លើផ្ទៃដី ៨៥៩០ ហិកតា



ប្រាក់_សុខុន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ..២២..អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើបំណាស់ថ្នាក់ជាទ្រព្យសម្បត្តិរបស់រដ្ឋ នូវទីតាំងដីសំរាប់ការសាងសង់ អគារប៉ុស្តិ៍ព្រំដែននៅច្រកព្រំដែនព្រែកចាក/លក នៅខេត្តកំពត

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈ ០២/នស/ ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ-បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសំណើរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

មាត្រា ១

ត្រូវបានកំណត់បរិវេណដី សំរាប់ធ្វើការសាងសង់អគារប៉ុស្តិ៍ត្រួតពិនិត្យព្រំដែននៅច្រកព្រំដែនព្រែកចាក/លក ដែលមានទីតាំងស្ថិតនៅក្នុងភូមិថ្កូវ ឃុំឬស្សីស្រុកខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត ។

មាត្រា ២

ត្រូវបានធ្វើចំណាត់ថ្នាក់បរិវេណដី ដូចមានបញ្ជាក់ក្នុងប្លង់ឧបសម្ព័ន្ធ ដែលមានផ្ទៃក្រឡាសរុបប្រមាណ ៤ ហិកតា ជាប្រភេទដីដែលមានលក្ខណៈសម្បត្តិជាទ្រព្យសាធារណៈរបស់រដ្ឋ ហើយមានទីតាំងស្ថិតនៅក្នុងភូមិថ្កូវ ឃុំឬស្សីស្រុកខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត ប្រកបដោយរបបគតិយុត្ត ដូចមានចែងក្នុងមាត្រា ១៥, មាត្រា ១៦, មាត្រា ១៧ នៃច្បាប់ភូមិបាល ចុះថ្ងៃទី ៣១ សីហា ឆ្នាំ ២០០១ និងមាននិយាមការដូចខាងក្រោមៈ

No.	Northing	Easting
A	1152674.131	440050.580
B	1152710.072	440026.595
C	1152749.356	440086.578
D	1152804.765	440049.506
E	1152929.861	440240.587
F	1152799.266	440327.740
G	1152683.628	440151.106

មាត្រា ៣

រាល់ការទន្ទ្រានយកដី ការដោះដូរ ការទិញលក់ ការផ្ទេរកម្មសិទ្ធិ ឬផ្ទេរសិទ្ធិកាន់កាប់ដី ការចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់នៃអចលនវត្ថុទាំងឡាយតាមគ្រប់រូបភាពទាំងអស់ ទោះស្របច្បាប់ក៏ដោយ ដែលស្ថិតនៅក្នុងបរិវេណដីបង្កកដូចបានពណ៌នាខាងលើនេះ និងការចេញលិខិតអនុញ្ញាតឱ្យសាងសង់ថ្មី ត្រូវបានហាមឃាត់ លើកលែងតែការផ្ទេរកម្មសិទ្ធិសម្រាប់បំរើផលប្រយោជន៍សាធារណៈ ។

រាល់ការបំពានលើបទប្បញ្ញត្តិ ដូចមានចែងខាងលើ អ្នកប្រព្រឹត្តល្មើសនឹងត្រូវទទួលទណ្ឌកម្មដែលមានចែងនៅក្នុងមាត្រា ២៥៩ នៃច្បាប់ភូមិបាល ចុះថ្ងៃទី ៣១ សីហា ឆ្នាំ ២០០១ ។

មាត្រា ៤

ម្ចាស់កម្មសិទ្ធិ ឬភោគីនៃដីធ្លី ក្នុងបរិវេណដែលនឹងត្រូវផ្ទេរប្រគល់ជូនរដ្ឋដើម្បីជាប្រយោជន៍សាធារណៈ នឹងទទួលបាននូវការទូទាត់សំណងពីគណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ដោយសារគំរោងការសាងសង់អគារប៉ុស្តិ៍ត្រួតពិនិត្យព្រំដែនខាងលើនេះ ។

មាត្រា ៥

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំងអស់ ដែលមានការពាក់ព័ន្ធព្រមទាំង អភិបាលខេត្តកំពត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៦

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមលោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសុវត្ថារា

៙៧

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **ធិបឌិន្ទ** ជូនមន្ត្រីរាជការ ចំនួន០៣រូប នៃខេត្តបន្ទាយមានជ័យ ដែលមានស្នាដៃល្អក្នុងការ បំពេញភារកិច្ច រួមចំណែកអភិវឌ្ឍន៍ខេត្ត លើគ្រប់វិស័យ តាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដូចមានរាយនាមខាងក្រោម :-

១-លោក	អ៊ី	ឡុង	អភិបាល នៃគណៈអភិបាលស្រុកមង្គលបូរី
២-លោក	អ៊ុក	កែវរតនៈ	នាយរងខុទ្ទកាល័យ សាលាខេត្ត
៣-លោក	ឥន្ទ	សុចិត្រ	អភិបាលរង នៃគណៈអភិបាលស្រុកមង្គលបូរី

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៧៧.អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូនមន្ត្រីរាជការ ចំនួន០៥រូប នៃខេត្តបន្ទាយមានជ័យ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច រួមចំណែកអភិវឌ្ឍន៍ខេត្ត លើគ្រប់វិស័យ តាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដូចមានរាយនាមខាង ក្រោម :-

១-លោក	មេ	ឡឹគីម	ប្រធានក្រុមប្រឹក្សា ស្រុកមង្គលបូរី
២-លោក	ឃូ	ពៅ	អភិបាល នៃគណៈអភិបាលស្រុកស្វាយចេក
៣-លោក	ម្លេត	តារី	នាយរងខុទ្ទកាល័យ សាលាខេត្ត
៤-លោក	លី	ស្រួយ	អភិបាលរង នៃគណៈអភិបាលស្រុកមង្គលបូរី
៥-លោក	ឈឺន	សុរិយា	ប្រធានការិយាល័យរបៀប និងឯកសារ សាលាខេត្ត

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៧៤. អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

ាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន១០រូប នៃខេត្តបន្ទាយមានជ័យ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច រួមចំណែកអភិវឌ្ឍន៍ខេត្តលើគ្រប់វិស័យ តាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដូចមានរាយនាមខាងក្រោម :-

ក.មេដាយមាសការងារ :

១-លោក រ័ត្ន ជាស៊ីណាច់ ប្រធានមន្ទីរ សាលាស្រុកមង្គលបូរី

២-អនុសេនីយ៍ឯក រស់ សំបូរ អត្តលេខ ១៤៥៣២១ ប្រធានអង្គភាពកងរាជអាវុធហត្ថ ស្រុកមង្គលបូរី

៣-វរសេនីយ៍ត្រី ផុន សាលឹម អត្តលេខ ៣១៩៥៦ អធិការនគរបាល ស្រុកមង្គលបូរី

៤-លោក ម៉ក់ គៀយ ប្រធានការិ.វប្បធម៌ និងវិចិត្រសិល្បៈ ស្រុកមង្គលបូរី

៥-លោក ទិត មន៍យ ប្រធានការិ.សុរិយោដី និងសំណង់ ស្រុកមង្គលបូរី

៦-លោក អេខ ប្រុសិទ្ធ អនុប្រធានការិ.សុរិយោដី និងសំណង់ ស្រុកមង្គលបូរី

ខ.មេដាយប្រាក់ការងារ :

១-លោក ហោ សុផាន់ណារ៉ាល់ ស្មៀន សាលាស្រុកមង្គលបូរី

២-លោក ញ៉ឹម គៀង ស្មៀន សាលាស្រុកមង្គលបូរី

៣-លោក ទុំ ឆាន ប្រធានការិយាល័យសង្គមកិច្ច ស្រុកមង្គលបូរី

គ.មេដាយសំរឹទ្ធការងារ :

-លោក មិន និមល អនុប្រធានការិយាល័យសង្គមកិច្ច ស្រុកមង្គលបូរី

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ៧៩. អនក្រ-បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

៙៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់អគ្គលេខាធិការរាជរដ្ឋាភិបាល

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន១៥រូប នៃអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច ដូចមានរាយនាមខាងក្រោម :-

ក.មេដាយមាសការងារ :

១-លោក	កុសល	ខេមរិន្ទ	ជំនួយការ អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
២-លោក	សយ	សុភារ៉ា	ជំនួយការ អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល

ខ.មេដាយប្រាក់ការងារ :

១-លោក	ម៉ែន	រដ្ឋា	មន្ត្រី អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
២-លោកស្រី	សៅ	ចំណាន	មន្ត្រី អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
៣-លោក	ឆឿង	អរុណ	មន្ត្រី អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល

គ.មេដាយសំរិទ្ធការងារ :

១-លោក	ម៉េង	ពេជ្រ	មន្ត្រី អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
២-លោកស្រី	មុំ	សុគន្ធា	មន្ត្រី អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
៣-លោក	ម៉ន	ធារសនា	មន្ត្រី អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
៤-លោកស្រី	ហ៊ុយ	ចំន្ទសោភា	មន្ត្រី អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
៥-លោកស្រី	ស៊ូ	ចំន្ទកេតសារណា	មន្ត្រី អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
៦-លោក	លឹម	ឧត្តមឧឡារៈ	មន្ត្រី អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
៧-លោក	ឈាង	ឈឹមបូរត	មន្ត្រី អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល

៨-លោក ម៉ៅ សុផាន់ណារ៉ា មន្ត្រី អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
៩-លោក ណី វណ្ណារិទ្ធ មន្ត្រី អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
១០-លោក ហេង នីរ៉ាដូ មន្ត្រី អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអគ្គលេខាធិការរាជរដ្ឋាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥១០ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការបញ្ចប់អាណត្តបេសកកម្មមន្ត្រីការទូត

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា ១ : ត្រូវបានផ្លាស់លោក **ឈី សំអុល** បច្ចុប្បន្នអគ្គកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងសៀងហៃ នៃសាធារណរដ្ឋប្រជាមានិតចិន ចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤១ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូត

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា ១ : ត្រូវបានផ្លាស់លោក **ឈន់ គមឃួន** បច្ចុប្បន្នអគ្គកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងហូជីមិញ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០១០

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥២. អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូត

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា ១ : ត្រូវបានផ្លាស់លោក **សុខ សោភ័ណ** បច្ចុប្បន្នអគ្គទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម ចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៣ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **សុខ ជា** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានច្បាប់ និងកុងស៊ុល នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាអគ្គកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងសៀងហៃ នៃសាធារណរដ្ឋប្រជាមានិតចិន ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៨៤ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **សម សារុត** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ-គណនេយ្យ នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាអគ្គកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងហូជីមិញ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១០

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៥ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / .០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **សំ ថន** បច្ចុប្បន្នអគ្គាធិការរង .នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាអគ្គទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៦. អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូន **Mr.TAKEUCHI HIROYUKI** ជំនាញការ **JICA** ប្រចាំអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមានស្នាដៃល្អក្នុងការចូលរួមជួយបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ និងផ្សព្វផ្សាយពីគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមស្ថាប័ន និងក្លឹបកំសាន្តនានា សរុបទឹកប្រាក់ចំនួន ៦៣៥.០០០ ដុល្លារអាមេរិក ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០៣ . សសរ

សេចក្ដីសម្រេច
ស្ដីពី
ការតែងតាំងសមាសភាពគណៈកម្មាធិការអន្តរក្រសួង សម្រាប់កំណត់អត្តសញ្ញាណកងកម្លាំងប្រដាប់អាវុធចូលនិវត្តន៍ ចូលបាត់បង់សមត្ថភាពការងារ ពិការ និងគ្រួសារយុទ្ធជនពលី មរណៈ ដែលត្រូវទទួលសម្បទានដីសង្គមកិច្ច

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស់/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

ស ម្រេ ច

ប្រការ ១ : ត្រូវបានបង្កើតគណៈកម្មាធិការអន្តរក្រសួង សម្រាប់កំណត់អត្តសញ្ញាណកងកម្លាំងប្រដាប់អាវុធចូលនិវត្តន៍ ចូលបាត់បង់សមត្ថភាពការងារ ពិការ និងគ្រួសារយុទ្ធជនពលី មរណៈ ដែលត្រូវទទួលសម្បទានដីសង្គមកិច្ច មានសមាសភាព និងភារកិច្ចដូចខាងក្រោម :

ក-សមាសភាព

១-ឯកឧត្តម	**អ៊ិត សំហេង**	រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	ប្រធាន
២-ឯកឧត្តម	**នាង ផាត**	រដ្ឋលេខាធិការក្រសួងការពារជាតិ	អនុប្រធាន
៣-ឯកឧត្តម	**តេង សាវង្ស**	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	អនុប្រធាន
៤-ឯកឧត្តម	**អ៊ុក រ៉ាប៊ុន**	រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៥-ឯកឧត្តម	**ប្រាក់ ហាម**	រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
៦-លោកជំទាវ	**ខេង សំវ៉ាដា**	រដ្ឋលេខាធិការក្រសួងកិច្ចការនារី	សមាជិក
៧-អភិបាល ឬអភិបាលរង នៃគណៈអភិបាលរាជធានី- ខេត្ត ដែលពាក់ព័ន្ធ			សមាជិក

ខ-ភារកិច្ច

-កំណត់ផែនការ ការងារស្តីពីការរៀបចំបញ្ជីឈ្មោះកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលត្រូវចូលនិវត្តន៍ ចូលបាត់បង់សមត្ថភាពការងារ ពិការ គ្រួសារយុទ្ធជនពលី មរណៈ ដែលត្រូវទទួលសម្បទានដី សង្គមកិច្ច

-ពិនិត្យសម្រេចលើបញ្ជីឈ្មោះកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងអតីតយុទ្ធជនដែលមានគ្រប់លក្ខណៈ ដើម្បីទទួលដីសម្បទានសង្គមកិច្ច បញ្ជូនទៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

-ណែនាំនីតិវិធីនៃការរៀបចំ កំណត់អត្តសញ្ញាណកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលត្រូវចូលនិវត្តន៍ ចូលបាត់បង់សមត្ថភាពការងារ ពិការ គ្រួសារយុទ្ធជនពលី មរណៈ ទៅគ្រប់ក្រសួងស្ថាប័ន ពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ

-រៀបចំបណ្តាញការងារកំណត់អត្តសញ្ញាណកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលត្រូវចូលនិវត្តន៍ ចូលបាត់បង់សមត្ថភាពការងារ ពិការ គ្រួសារយុទ្ធជនពលី មរណៈ ពីថ្នាក់ជាតិដល់ក្រសួងស្ថាប័ន រាជធានី ខេត្ត អង្គភាព និងមូលដ្ឋាន

-ត្រួតពិនិត្យ និង ក្រើនរំលឹកគ្រប់ក្រសួងស្ថាប័ន អង្គភាព អាជ្ញាធរពាក់ព័ន្ធគ្រប់ថ្នាក់ដើម្បីជំរុញការអនុវត្ត ផែនការឱ្យបានល្អ

-បូកសរុប និងរាយការណ៍លទ្ធផលការងារ និងស្នើសុំគោលការណ៍ជាបន្តបន្ទាប់ពីប្រមុខរាជរដ្ឋាភិបាល

-គណៈកម្មាធិការត្រូវកោះប្រជុំទៀងទាត់បីខែម្តង និងអាចប្រជុំវិសាមញ្ញតាមការចាំបាច់

-អនុប្រធាន សមាជិកគណៈកម្មាធិការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន

គណៈកម្មាធិការអន្តរក្រសួងមានសិទ្ធិប្រើប្រាស់ត្រារបស់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

ប្រការ ២ : បង្កើតលេខាធិការដ្ឋានដើម្បីជាជំនួយការដល់គណៈកម្មាធិការអន្តរក្រសួង ដែលមានសមាសភាព និងភារកិច្ច ដូចខាងក្រោម :

ក-សមាសភាព

១-ឯកឧត្តម **យី យ៉ូន**	រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	ប្រធាន
២-ឯកឧត្តម **ឃួន វ៉ាន់ន**	អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	អនុប្រធាន
៣-ឧត្តមសេនីយ៍ទោ **ទូច សុវណ្ណារិទ្ធ**	ប្រធាននាយកដ្ឋានសោធននិវត្តន៍ ក្រសួងការពារជាតិ	អនុប្រធាន
៤-ឧត្តមសេនីយ៍ត្រី **ហុក ច័ន្ទវណ្ណា**	អនុប្រធាននាយកដ្ឋានបុគ្គលិក នៃអគ្គស្នងការនគរបាលជាតិ ក្រសួងមហាផ្ទៃ	អនុប្រធាន
៥-លោក **គីម ហុង**	អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស នៃក្រសួង ស.អ.យ	លេខាធិការ
៦-លោក **ហែម ចូរ៉ា**	ប្រធាននាយកដ្ឋានសោធនអតីតយុទ្ធជន នៃក្រសួង ស.អ.យ	សមាជិក
៧-លោក **មាស ឈាន**	ប្រធាននាយកដ្ឋានអភិវឌ្ឍន៍អតីតយុទ្ធជន នៃក្រសួង ស.អ.យ	សមាជិក
៨-លោក **នេត មុន្នី**	ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៩-លោក **សារេត បូរាមី**	អគ្គលេខាធិការរងអចិន្ត្រៃយ៍-អគសសជ ក្រសួងដែនដី នគរូបនីយកម្មនិង សំណង់	សមាជិក
១០-លោកស្រី **សៅ ស៊ីម្ម**	អនុប្រធាននាយកដ្ឋានសមភាពយេនឌ័រ ក្រសួងកិច្ចការនារី	សមាជិក
១១-លោកស្រី **គីម ច័ន្ទសុលីណា**	ប្រធានការិយាល័យជីវភាព និងឥណទានអតីតយុទ្ធជន នៃក្រសួង ស.អ.យ	សមាជិក
១២-លោក **គីម តេង**	ប្រធានការិយាល័យគ្រប់គ្រងទិន្នន័យនៃក្រសួងស.អ.យ	សមាជិក

ខ-ភារកិច្ច

-ចាត់ចែងអនុវត្តការងារប្រចាំថ្ងៃរបស់គណៈកម្មាធិការអន្តរក្រសួង

-រៀបចំកិច្ចប្រជុំរបស់គណៈកម្មាធិការអន្តរក្រសួង

-តាមដានត្រួតពិនិត្យ ការអនុវត្តផែនការ និងគោលការណ៍ផ្សេងៗរបស់គណៈកម្មាធិការអន្តរក្រសួង

-រៀបចំរបាយការណ៍បូកសរុប កំណត់ហេតុ និងព្រាងឯកសារផ្សេងៗ ជូនគណៈកម្មាធិការអន្តរក្រសួង

-អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់គណៈកម្មាធិការអន្តរក្រសួង

-លេខាធិការដ្ឋានមានទីតាំងនៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

ប្រការ ៣ : បង្កើតគណៈកម្មការរាជធានី ខេត្ត កំណត់អត្តសញ្ញាណកងកម្លាំងប្រដាប់អាវុធចូលនិវត្តន៍ ចូលបាត់បង់សមត្ថភាពការងារ ពិការ និងគ្រួសារយុទ្ធជនពលី មរណៈ ដែលត្រូវទទួលសម្បទានដីសង្គមកិច្ច ដែលមានសមាសភាព និងភារកិច្ចដូចខាង ក្រោម :

ក-សមាសភាព

១-អភិបាលរង នៃគណៈអភិបាលរាជធានី- ខេត្ត	ប្រធាន
២-ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	អនុប្រធាន
៣-មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង	អនុប្រធាន
៤-ស្នងការនគបាលរាជធានី -ខេត្ត	អនុប្រធាន
៥-មេបញ្ជាការកងរាជអាវុធហត្ថរាជធានី -ខេត្ត	អនុប្រធាន
៦-មេបញ្ជាការកងឯកភាពដែលមានទីតាំងនៅរាជធានី-ខេត្ត	សមាជិក
៧-អនុប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៨-អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
៩-អនុប្រធានមន្ទីរកិច្ចការនារី	សមាជិក
១០-អភិបាល ក្រុង ស្រុក ខណ្ឌ ដែលពាក់ព័ន្ធ	សមាជិក

ខ-ភារកិច្ច

គណៈកម្មការរាជធានី-ខេត្ត កំណត់អត្តសញ្ញាណកងកម្លាំងប្រដាប់អាវុធចូលនិវត្តន៍ ចូលបាត់បង់សមត្ថភាពការងារ ពិការ និងគ្រួសារយុទ្ធជនពលី មរណៈ ដែលត្រូវទទួលសម្បទានដីសង្គមកិច្ច មានភារកិច្ចដូចខាងក្រោម ៖

-ចាត់ចែងអនុវត្តផែនការ និង គោលការណ៍ណែនាំរបស់គណៈកម្មាធិការអន្តរក្រសួង

-រៀបចំផែនការកម្មវិធីការងារជាក់ស្តែងរបស់រាជធានី -ខេត្ត

-ដឹកនាំ ណែនាំ អង្គភាព អាជ្ញាធរពាក់ព័ន្ធក្នុងការអនុវត្តគោលការណ៍ណែនាំរបស់ថ្នាក់លើ និងផែនការ ការងាររបស់រាជធានី -ខេត្ត

-ធ្វើរបាយការណ៍បូកសរុប និងរាយការណ៍លទ្ធផលការងារជូនគណៈកម្មាធិការអន្តរក្រសួង

-ដោះស្រាយករណីចៃដន្យផ្សេងៗដែលកើតមានជាយថាហេតុ របស់រាជធានី -ខេត្ត នីមួយៗ

-គណៈកម្មការរាជធានី -ខេត្ត ត្រូវប្រជុំទៀតទាត់ ៣ ខែម្តង ក្នុងករណីចាំបាច់អាចកោះប្រជុំជាបន្ទាន់

-អនុប្រធាន និងសមាជិក ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន

គណៈកម្មការរាជធានី - ខេត្ត ត្រូវបង្កើតដោយដីការបស់អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងមានសិទ្ធិប្រើប្រាស់ត្រារបស់សាលារាជធានី - ខេត្ត ។

ប្រការ ៤ ៖ បង្កើតលេខាធិការដ្ឋានជាជំនួយការគណៈកម្មការរាជធានី - ខេត្ត ដែលមានសមាសភាពដូចខាងក្រោម ៖

១-ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	ប្រធាន
២-នាយរងខុទ្ទកាល័យសាលារាជធានី ខេត្ត	អនុប្រធាន
៣-អនុប្រធានមន្ទីរ ស.អ.យ ទទួលបន្ទុកអតីតយុទ្ធជន	អនុប្រធាន
៤-នាយការិយាល័យ គោលនយោបាយសឹករង	អនុប្រធាន
៥-នាយការិយាល័យ គោលនយោបាយស្នងការនគរបាល	អនុប្រធាន
៦-នាយការិយាល័យ គោលនយោបាយកងរាជអាវុធហត្ថ	អនុប្រធាន
៧-តំណាង មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក

៨-តំណាងមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ សមាជិក

៩-តំណាងមន្ទីរកិច្ចការនារី សមាជិក

១០-តំណាងក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ពាក់ព័ន្ធ សមាជិក

+លេខាធិការដ្ឋានមានសិទ្ធិប្រើប្រាស់ត្រារបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី -ខេត្ត ដើម្បីអនុវត្តការងារ

+លេខាធិការដ្ឋានមានទីតាំងនៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី-ខេត្ត ។

ប្រការ ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលរាជធានី -ខេត្ត ពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ និងប្រការ ២ ត្រូវអនុវត្តសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ២០១០

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

លេខ : ០១៤ ឧរថ.ក.ឧ. ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែមករា ឆ្នាំ២០១០

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញលិខិតលេខ ២៥៨១/០៩ គ.វ.ក ចុះថ្ងៃទី៣០.១១.២០០៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន កូហ្គីដ (ខេមបូឌា) ចុះថ្ងៃទី២៣.១១.២០០៩

សំ រេ ច

ប្រការ១ :

-អនុញ្ញាតឱ្យក្រុមហ៊ុន កូហ្គីដ (ខេមបូឌា) តំណាងដោយ លោក KYE KYUNG SUNG សញ្ជាតិកូរ៉េ អាយុ៦១ឆ្នាំ កាន់លិខិតឆ្លងដែនលេខ SC2190430 ចុះថ្ងៃទី១៨.០២.២០០៩ មានអាសយដ្ឋានបច្ចុប្បន្ន : SINBANPO APT 18 CHA336-1001, 52 JAMWON-DONG, SEOCHO-GU, SEOUL, KOREA. ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម :

ល.រ ឈ្មោះផលិតផល លេខចុះបញ្ជីផលិតផល ISIC Code

ពោត (ស្ងួត) **៣១១៤**

-ផ្ទាកឈ្មោះ រោងចក្រ : " **គូហ្គីដ (ខេមបូឌា) (KOGID (CAMBODIA) Co., Ltd.)**"

-ទីតាំងរោងចក្រ : ***" ផ្លូវ ៥៧ ភូមិជាមន្ត្រី ឃុំក្រែង ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង"***

ប្រការ២ :

-ម្ចាស់រោងចក្រត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឱ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណាផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណី ដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣ :

-ម្ចាស់រោងចក្រ ត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យ ដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសំរេចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម លេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានាស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤ :

ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬប្រគល់សិទ្ធិឱ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប៉ុន្តែក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និង គុណភាពផលិតផល របស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។៚

ប្រការ៥ :

ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាស ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬ ចាត់ឱ្យមករៀបចំរោងចក្របានឡើយ ។

ប្រការ៦ :

ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីខាងមុខរោងចក្រ ។

ប្រការ៧:

-មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹង ឱ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឱ្យម្ចាស់រោងចក្រ មានសុពលភាព ០៣ឆ្នាំ តាមលក្ខខណ្ឌដូចខាងក្រោម :

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និង ផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូ ដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់នូវកាតព្វកិច្ចបង់កម្រៃសេវាបញ្ជិកាកម្មរោងចក្រប្រចាំ ០៣ឆ្នាំ។

ប្រការ៨ :

-ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចាំបាច់នៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាពនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាពទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩ :

-ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឱ្យអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយនៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកឱ្យអគ្គនាយកដ្ឋានឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅក្នុងអំឡុងពេលសប្តាហ៍ទីមួយនៃខែមករានៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រនឹងត្រូវទទួលទោសប្បញ្ញត្តិតាមមាត្រា ៤៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០:

រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្មស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និង ការចុះបញ្ជីផលិតផល ។

ប្រការ១១:

លក្ខខណ្ឌនានា របស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ ។

ប្រការ១២:

ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល ១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣:

-ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចស្របតាមមាត្រា ៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និង សិប្បកម្មឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹងមកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

-ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល រយៈពេល១ខែ យ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រ ជាស្ថាពរ ។

ប្រការ១៤:

អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តបាត់ដំបង និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀង១ខ្លួន ។

ប្រការ១៥:

ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ_សែម

ចម្លងជូន:

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាខេត្តបាត់ដំបង
" ដើម្បីជូនជ្រាប "
-ដូចប្រការ១៥ " ដើម្បីអនុវត្ត "
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ០៦៥ ឧស្ម.ករ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែមករា ឆ្នាំ២០១០

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញលិខិតលេខ ២៦០០/០៩ ក.អ.ក ចុះថ្ងៃទី០២.១២.២០០៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន យូ ភី ជី ខូ អិលធីឌី ចុះថ្ងៃទី១៤.០៩.២០០៩

សំ រេ ច

ប្រការ១ :

- អនុញ្ញាតឱ្យក្រុមហ៊ុន យូ ភី ជី ខូ អិលធីឌី តំណាងដោយ លោក ឈុន ស្រ៊ា សញ្ជាតិខ្មែរ អាយុ៥៦ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ 060014669 ចុះថ្ងៃទី២៤.០៨.២០០០ មានអាសយដ្ឋានបច្ចុប្បន្ន : ភូមិ៣ ឃុំវាលវង់ ស្រុកកំពង់ចាម ខេត្តកំពង់ចាម ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម :

ឈ្មោះផលិតផល	លេខចុះបញ្ជីផលិតផល ISIC Code
ប្រេងរំអិល	**៣៥៣០**

-ផ្លាកឈ្មោះ រោងចក្រ : " **យូ ភី ជី ខូ អិលធីឌី (U P G CO., LTD.)**"

-ទីតាំងរោងចក្រ : "***ភូមិព្រែកព្រៃ ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល***" ។

ប្រការ២ :

-ម្ចាស់រោងចក្រត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឱ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណាផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណី ដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣ :

-ម្ចាស់រោងចក្រ ត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យ ដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសំរេចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម លេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានាស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤ :

ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬប្រគល់សិទ្ធិឱ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប៉ុន្តែក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និង គុណភាពផលិតផល របស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។/.

ប្រការ៥ :

ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាស ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬ ចាត់ឱ្យមករៀបចំរោងចក្របានឡើយ ។

ប្រការ៦ :

ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីខាងមុខរោងចក្រ ។

ប្រការ៧:

-មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនយ៉ាងតិច ១៥ថ្ងៃ និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឱ្យម្ចាស់រោងចក្រ មានសុពលភាព ០៣ឆ្នាំ តាមលក្ខខណ្ឌដូចខាងក្រោម :

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និង ផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូ ដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់នូវកាតព្វកិច្ចបង់កម្រៃសេវាបញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ឆ្នាំ។

ប្រការ៨ :

-ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

